ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរណែនាំ

# ស្តីពី

# គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

Www.KhmerFamous.Com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

សារាចរណែនាំ/១៣១ កសក.សរណន/១០ មេសា ១៩៩០/

## ស្តីពីគោលនយោបាយ គ្រប់គ្រង និង ប្រើប្រាស់ដីធ្លី

យោងស្មារតីសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ០៣ សណន ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងលិខិតលេខ ៤៨៥ កសក.មរប ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ១៩៩០ របស់ក្រសួងកសិកម្ម ស្តីពីការពន្យាពេលសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ក្រសួងកសិកម្ម សង្កេតឃើញថា ខេត្ត-ក្រុងមួយចំនួនបានខិតខំយកចិត្តទុកដាក់ជំរុញការអនុវត្តបានល្អបង្គួរដោយរៀបចំបណ្តាញទទួលពាក្យពីប្រជាជន គ្រប់គ្រងចំណូលពីការដាក់ពាក្យ និងបណ្តាវិធានការជាក់ស្តែងផ្សេងៗទៀត មានការបើកវគ្គផ្សព្វផ្សាយ ការបញ្ចុះកម្មាភិបាលចុះជួយ ការត្រួតពិនិត្យ ។ល ។ ទន្ទឹមនោះ ក៏មានខេត្ត-ក្រុងខ្លះមិនទាន់អនុវត្តបានល្អនិងសមស្របនៅឡើយ ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្មសូមធ្វើការណែនាំលំអិត ដល់គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ដូចតទៅ:

១- ការអនុវត្តជំហានទី ១

ជំហាននេះ គឺសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ដែលត្រូវបិទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩០ ។ ដូច្នេះបណ្តាខេត្ត-ក្រុង ត្រូវខិតខំយ៉ាងណាអនុវត្តអោយបានសំរេចក្នុងរយៈពេលនេះ ដោយមិនអនុញ្ញាតអោយពន្យាពេលទទួលពាក្យជាលើកទី ២ទៀតទេ ។

ក្នុងការទទួលពាក្យ មូលដ្ឋានស្រុក ខ័ណ្ឌ ជួបការលំបាកអំពីបញ្ហាចុះហត្ថលេខាលើបង្កាន់ដៃបង់ប្រាក់គ្រប់ ប្រភេទ ។ ក្រសួងកសិកម្ម សូមជំរាបថា ក្នុងការចុះហត្ថលេខានេះមិនមែនសំដៅតែប្រធានគណៈកម្មាធិការប្រជាជនស្រុកតែម្នាក់ទេ គឺបណ្តាសមមិត្តក្នុងជួរគណៈកម្មាធិការប្រជាជនស្រុក ខណ្ឌ " ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍" អាចចុះហត្ថលេខាបាន ។ តែបញ្ហាដែលត្រូវជៀសវាង គឺមិនអនុញ្ញាត អោយឆ្លាក់ត្រាហត្ថលេខាបោះលើបង្កាន់ដៃ ឬអូសស្តង់ស៊ីលហត្ថលេខាផ្តិតលើបង្កាន់ដៃទេ ។

ទន្ទឹមនឹងនោះសូមគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ស្រុក ខណ្ឌ ជំរុញការទូទាត់ឯកសារ និងការបង់ប្រាក់នៅធនាគារ បណ្តាចំណូលពីការចេញបង្កាន់ដៃ "ក,ខ,គ" ដែលមានចែងក្នុងប្រកាសរួមរបស់ក្រសួង កសិកម្ម និងហិរញ្ញវត្ថុលេខ ០០៦០ ប្រក.កសក ០០១ កហវ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៨៩ ស្រាប់ "តារាងភ្ជាប់" ។

២- ការអនុវត្តជំហានទី ២

ជំហាននេះគឺសម័យធ្វើអង្កេតវាស់វែង និង ចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីធ្វើជូនប្រជាជន ដែលត្រូវចាប់ដំណើរការបន្ទាប់ពីបិទសម័យទទួលពាក្យ ។

ក្នុងការត្រៀមអនុវត្តជំហាននេះ ក្រសួងកសិកម្មបើកវគ្គវិក្រិត្យការជំនាញសុរិយោដី និងច្បាប់រយៈពេល ៣៥ថ្ងៃ "ពីថ្ងៃ ១៩-២ ដល់ ២៤-៣-៩០" ជូនកម្មាភិបាលខេត្ត-ក្រុងទាំង២១ រួចហើយ ។ ដូច្នេះគ្រប់ ខេត្ត-ក្រុងត្រូវចាត់រៀបចំបើកវគ្គវិក្រិត្យការបន្តជូនដល់កម្មាភិបាល គ្រប់ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បី មានការយល់ដឹងងាយស្រួលអនុវត្តជំហានទី ២នេះ ។

ម្យ៉ាងទៀត ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសរុបរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងកសិកម្ម សូមអោយបណ្តាខេត្ត-ក្រុង ធ្វើរបាយការណ៍អំពីសភាពការណ៍អនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីតាមចំណុចដូចខាងក្រោម :

- ការទទួលពាក្យសរុបក្នុងខេត្ត-ក្រុង............ ត្រូវជា.................. កន្លែង
- ការចេញបង្កាន់ដៃបង់ប្រាក់ "ក"................ បង្កាន់ដៃត្រូវជា....... រៀល
- ការចេញបង្កាន់ដៃបង់ប្រាក់ "ខ"................ បង្កាន់ដៃត្រូវជា....... រៀល

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

- ការចេញបង្កាន់ដៃបង់ប្រាក់ "គ"................. បង្កាន់ដៃត្រូវជា....... រៀល
- ការទូទាត់ថ្លៃពាក្យស្នើ.............................. រៀលត្រូវជា............ ភាគរយ
- ការវាយតំលៃ :
- ការលំបាក និងការងាយស្រួល
- សំណូមពរ
- សន្និដ្ឋាន

របាយការណ៍នេះស្នើផ្ញើមកដល់ក្រសួងកសិកម្មមុនថ្ងៃ ១០ ខែមិថុនា ឆ្នាំ១៩៩០

ក្រសួងកសិកម្មមានសង្ឃឹមយ៉ាងមាំថា សមមិត្តប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង នឹង ខិតខំជំរុញអនុវត្តអោយបានសំរេចតាមស្មារតីសេចក្តីសំរេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី ២ ស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីជាពុំខាន ។